# ផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៩ និង ២០២០

"ការរៀបចំមូលដ្ឋានសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤"

# មាតិកា


១. សេចក្តីផ្តើម

២. គោលដៅ និងសកម្មភាពអាទិភាព

៣. ថវិកាសម្រាប់អនុវត្តផែនការ

៤. យន្តការនៃការអនុវត្តផែនការ

៥. កាលវិភាគ និងការតាមដានត្រួតពិនិត្យការអនុវត្តផែនការ

៦. ឯកសារយោង

## ១. សេចក្តីផ្តើម

ផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៩ និង ២០២០ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥ ក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ ផែនការនេះក៏នឹងបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យ ទ-ប.គ.ព ឆ្នាំ២០២០ ធ្វើយ៉ាងណាសំដៅដល់ការអភិវឌ្ឍវិស័យ ទ-ប.គ.ព មានសង្គតិភាព ភាពប្រទាក់ក្រឡាជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព។

ដោយមើលឃើញពីការវិវត្តរបស់ឧស្សាហកម្មបច្ចេកវិទ្យានៅលើពិភពលោក យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់ចេញនូវអាទិភាពមួយចំនួនសម្រាប់ត្រៀមខ្លួនទទួលយកនូវសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤។ សកម្មភាពអាទិភាពមួយចំនួនអាចប្រើប្រាស់មូលនិធិសម្រាប់ទ្រទ្រង់សកម្មភាពបានព្រោះថាអាទិភាពទាំងនោះសមស្របជាមួយនឹងវត្ថុបំណងដែលបានចែងក្នុងអនុក្រឹត្យស្តីពីការកំណត់យន្តការគ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ អាទិភាពទាំងនោះមានដូចជា៖

- ការអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទូលំទូលាយ និងការបញ្ចូលការប្រើប្រាស់ និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ រួមទាំងការបង្កើតយន្តការភាពជាដៃគូរវាងធុរកិច្ច និងគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ។
- ការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថលដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ, ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តការសហប្រតិបត្តិការសហគ្រិនភាពក្នុងក្របខណ្ឌរាជរដ្ឋាភិបាលឬភាពជាដៃគូជាមួយវិស័យឯកជន។

ការដាក់ចេញនូវកម្មវិធីឬគម្រោងជាក់លាក់ ទៅតាមអាទិភាពខាងលើ នឹងធ្វើឡើងដើម្បីដោះស្រាយបញ្ហាប្រឈមជាក់ស្តែង និងបន្ទាន់ដែលទាមទារឱ្យមានបទអន្តរាគមន៍ជាក់លាក់ពីរាជរដ្ឋាភិបាល។ បញ្ហាទាំងនោះត្រូវបានរកឃើញនិងលើកយោបល់ក្នុងរបាយការណ៍ស្តីពី "Cambodia's Vibrant Tech Startup Ecosystem 2018" ដោយក្រុមហ៊ុនធុរកិច្ចថ្មីៗ សហគ្រិនក្នុងស្រុក អ្នកវិនិយោគ និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្នុងនោះ ដើម្បីអាចជាប្រទេសដែលមានសក្តានុពល និងរក្សាលទ្ធភាពប្រកួតប្រជែងក្នុងថ្នាក់តំបន់ កម្ពុជាត្រូវដោះស្រាយបញ្ហាកង្វះខាតធនធានមនុស្សជំនាញផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងស្រុកទាំងបរិមាណ និងគុណភាព, ការបណ្តុះបណ្តាលជំនាញមិនមានលក្ខណៈទាន់សម័យដែលអាចឆ្លើយតបឆាប់រហ័សនឹងការវិវត្តរបស់បច្ចេកវិទ្យាបាន ភាពខ្វះខាតអ្នកជួយដឹកនាំបំភ្លឺផ្លូវក្នុងការធ្វើជំនួញឬការបង្កើតនិងពង្រីកអាជីវកម្មឌីជីថល ខ្វះកម្មវិធីបណ្តុះបណ្តាលបង្កើតជំនួញដែលមានគុណភាព និងមិនបានគិតគូរពីតំណភ្ជាប់សមភាពយេនឌ័រជាមួយការអភិវឌ្ឍប្រព័ន្ធអេកូស៊ីស្ទឹមទាំងមូលជាដើម។ល។ អាស្រ័យហេតុនេះ ការដាក់ចេញគោលដៅ កម្មវិធីក្នុងផែនការ ព្រមទាំងការផ្តល់មូលនិធិ ស.អ. សម្រាប់អនុវត្តគម្រោងនឹងធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីអន្តរាគមន៍របស់រាជរដ្ឋាភិបាលលើបញ្ហាដែលបានលើកឡើងខាងលើ។

## ២. គោលដៅ និងសកម្មភាពអាទិភាព

ផែនការនេះដាក់ចេញនូវគោលដៅចំនួនបីដូចខាងក្រោម និងមាននូវសកម្មភាពសំខាន់ៗឆ្លើយតបទៅនឹងគោលដៅដូចខាងក្រោម៖

- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបង្កើនទាំងបរិមាណ គុណភាព និងការបណ្តុះថ្នាលមុនការចាប់យកជំនាញ។
- ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ នវានុវត្តន៍ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ការងារស្រាវជ្រាវព្រមទាំងលើកទឹកចិត្តដល់ការស្រាវជ្រាវអន្តរវិស័យនានា។
- ជំរុញការបង្កើតអាជីវកម្មថ្មីៗខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីបន្តនវានុវត្តន៍ ការច្នៃប្រឌិត ការទាក់ទាញទុន និងកំណើនសេដ្ឋកិច្ចក្នុងយុគសម័យឌីជីថល។

### ១.) ជំរុញការអភិវឌ្ឍធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

| ល.រ | សកម្មភាពអាទិភាព | ទិសដៅនៃការផ្តល់ហិរញ្ញប្បទាន | សូចនាករ |
|---|---|---|---|
| ១ | សិក្សាពីគម្លាតជំនាញនៅកម្ពុជា និងតម្រូវការជំនាញក្នុងទីផ្សារបច្ចេកវិទ្យា ប.គ.ព. នាពេលបច្ចុប្បន្ន | សកម្មភាពទាំងឡាយដែលរៀបចំដើម្បីសិក្សាស្វែងរកគម្លាតរវាងជំនាញ ប.គ.ព. នៅកម្ពុជា និងទីផ្សារបច្ចេកវិទ្យា ប.គ.ព. ព្រមទាំងផ្តល់អនុសាសន៍ក្នុងការកាត់បន្ថយគម្លាតជំនាញ | របាយការណ៍សិក្សាស្រាវជ្រាវ និងអនុសាសន៍ |
| ២ | ពង្រីកហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាលបច្ចេកវិទ្យា ប.គ.ព.និងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គាំទ្រការអប់រំនៅតាមមធ្យមសិក្សា | គម្រោងទាំងឡាយណាដែលរៀបចំដំឡើងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាតាមសាលារៀន ឬគម្រោងដែលពាក់ព័ន្ធនឹងការបង្កើតមាតិកាឌីជីថលសម្រាប់គាំទ្រការអប់រំចំណេះទូទៅ | -សាលារៀនចំនួន ២០ ត្រូវបានបំពាក់ឧបករណ៍បរិក្ខារបច្ចេកវិទ្យា<br>-មាតិកាឌីជីថលសម្រាប់ការអប់រំចំណេះទូទៅចំនួន ៥ ត្រូវបានអភិវឌ្ឍន៍ និងដាក់បញ្ចូលក្នុងប្រព័ន្ធ |
| ៣ | បង្កើនចំនួននិស្សិតចាប់យកមុខវិជ្ជាជំនាញ ប.គ.ព. និងការស្រាវជ្រាវមុខជំនាញ ប.គ.ព. | កម្មវិធីទាំងឡាយណាដែលមានគោលបំណងលើកទឹកចិត្តនិងផ្សព្វផ្សាយជំរុញឱ្យសិស្សបញ្ចប់មធ្យមសិក្សាចាប់យកមុខជំនាញ ប.គ.ព. រួមទាំងគម្រោងផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិត។ | បរិញ្ញាបត្រ ចំនួន១០០កន្លែង/ ឆ្នាំ<br>អនុបណ្ឌិតក្នុងនិងក្រៅប្រទេស១០/ ឆ្នាំ<br>អាហារូបករណ៍ថ្នាក់បណ្ឌិតចំនួន៥/ ឆ្នាំ<br>កម្មវិធីផ្សព្វផ្សាយជំនាញចំនួន ១/ ឆ្នាំ |
| ៤ | ជំរុញការផ្តល់ជំនាញ ប.គ.ព. ជាក់ស្តែង និងឯកទេស សម្រាប់សិស្ស និស្សិត និងមន្ត្រីជំនាញ | កម្មវិធីបណ្តុះបណ្តាលជំនាញ ប.គ.ព. តាមទិដ្ឋភាពការងារជាក់ស្តែង កម្មវិធីចុះកម្មសិក្សា ដែលកាត់បន្ថយគម្លាតចំណេះដឹងទ្រឹស្តី និងការអនុវត្តជាក់ស្តែង | កម្មវិធី ១០ អាចទទួលបានការផ្គត់ផ្គង់ហិរញ្ញវត្ថុជារៀងរាល់ឆ្នាំ |

### ២.) ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ នវានុវត្តន៍ ខាងផ្នែក ប.គ.ព.

| ល.រ | សកម្មភាពអាទិភាព | ទិសដៅនៃការផ្តល់ហិរញ្ញប្បទាន | សូចនាករ |
|---|---|---|---|
| ១ | បន្តការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងវិស័យ ប.គ.ព. | សាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍លើវិស័យ ប.គ.ព. ព្រមទាំងបន្ទប់ពិសោធន៍នានាលើបច្ចេកវិទ្យាថ្មីៗ | មជ្ឈមណ្ឌលស្រាវជ្រាវនិងបន្ទប់ពិសោធន៍ចំនួន ៣ ត្រូវបានបង្កើតឡើង |

| | | | |
|---|---|---|---|
| ២ | លើកទឹកចិត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍ខាងផ្នែក ប.គ.ព. | ការសិក្សាស្រាវជ្រាវលើផ្នែកផ្សេងកម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា ប.គ.ព. សម្រាប់អភិវឌ្ឍលើវិស័យអប់រំ សុខាភិបាល គមនាគមន៍ កសិកម្ម និងឧស្សាហកម្ម និងបច្ចេកវិទ្យាថ្មីៗ | ការស្រាវជ្រាវចំនួន៣ បានទទួលហិរញ្ញប្បទាន |

## ៣.) ជំរុញការអភិវឌ្ឍបរិស្ថានអាជីវកម្មថ្មីៗលើវិស័យ ប.គ.ព.

| ល.រ | សកម្មភាពអាទិភាព | ទិសដៅនៃការផ្តល់ហិរញ្ញប្បទាន | សូចនាករ |
|---|---|---|---|
| ១ | ជំរុញការបង្កើតមុខរបរថ្មីខាងផ្នែកបច្ចេក-វិទ្យាគមនាគមន៍ និងព័ត៌មាន | កម្មវិធីបណ្តុះបណ្តាល កម្មវិធីប្រឹក្សាយោបល់ឬកម្មវិធីទាំងឡាយដែលផ្តោតលើការបង្កើតមុខរបរថ្មី ឬកម្មវិធីប្រកួតប្រជែងគំនិត ដោយមានទាំងសកម្មភាពខ្លីៗ ការបណ្តុះបណ្តាល ការជំរុញការចូលរួមបង្កើតមុខរបរ | កម្មវិធីភ្ញាស់គំនិតចំនួន១០ ត្រូវបានធ្វើឡើង |
| ២ | ជំរុញការបង្កើតបណ្តាញទំនាក់ទំនងសម្រាប់ក្រុមហ៊ុនទើបបង្កើតថ្មីដើម្បីស្វែងរកទុននិងពង្រីកទីផ្សារ | កម្មវិធីទាំងឡាយណាដែលរៀបចំឡើងជាលក្ខណៈការប្រកួតប្រជែងក្តី ការតាំងបង្ហាញផលិតផល ឬការតភ្ជាប់បណ្តាញទំនាក់ទំនងនិងពាំនាំក្រុមហ៊ុនក្នុងស្រុកទៅលើឆាកអន្តរជាតិ ស្វែងរកដៃគូវិនិយោគ ឬពង្រីកទីផ្សារ | កម្មវិធីទំនាក់ទំនងក្នុងនិងក្រៅប្រទេសចំនួន៥/១ឆ្នាំ |
| ៣ | ជំរុញការតភ្ជាប់អាជីវកម្មបច្ចេកវិទ្យាថ្មីៗក្នុងការផ្តល់សេវារដ្ឋាភិបាលឌីជីថល | កម្មវិធីទាំងឡាយដែលរៀបចំឡើងបើកផ្តល់ឱកាសដល់អាជីវកម្មបច្ចេកវិទ្យាថ្មីៗក្នុងស្រុក(រដ្ឋាភិបាល ឬវិស័យឯកជន) ស្វែងរកដំណោះស្រាយបច្ចេកវិទ្យាសម្រាប់សេវារដ្ឋាភិបាលឌីជីថល និងពង្រីកសេវាដែលមានស្រាប់ | កម្មវិធី ឬអាជីវកម្មបច្ចេកវិទ្យាចំនួន២ នឹងទទួលបានមូលនិធិ ស.អ. សម្រាប់អនុវត្តកិច្ចការរបស់ខ្លួន |

## ៣. ថវិកាសម្រាប់អនុវត្តផែនការ

ថវិកាសម្រាប់អនុវត្តផែនការនេះ គឺជាថវិកាដែលបានមកពីមូលនិធិស.អ. សម្រាប់ឆ្នាំ២០១៩ និង២០២០។ ក្រុមប្រឹក្សាមូលនិធិ ស.អ. នឹងតម្រង់ទិសនៃការប្រើប្រាស់មូលនិធិ ស.អ. ទាំងចំណែកស្នើសុំទូទាត់មុន ២០% និងផ្នែកបង់ចូលមូលនិធិ មកអនុវត្តគម្រោងក្នុងទិសដៅខាងលើ។

## ៤. យន្តការសម្រាប់អនុវត្តផែនការ

ដើម្បីធានាពីតម្លាភាព ប្រសិទ្ធភាព នៃការអនុវត្តគម្រោង គម្រោងទាំងអស់នេះនឹងបើកទូលាយឱ្យមានការដាក់ស្នើសុំពីស្ថាប័នពាក់ព័ន្ធទាំងឡាយណាដែលមានគុណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងអនុក្រឹត្យស្តីពី "ការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"។ រាល់សំណើសុំគម្រោងដែលត្រូវបានអនុម័តរួចត្រូវរៀបចំកិច្ចសន្យាលម្អិត ដោយមានបញ្ជាក់ពីការព្រមព្រៀងលើយន្តការតាមដានត្រួតពិនិត្យគម្រោងជាមួយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាមូលនិធិ ស.អ. ។

អ្នកអនុវត្តគម្រោងត្រូវគោរពតាមលក្ខខណ្ឌនានាដែលចែងក្នុងសេចក្តីសម្រេចស្តីពីគោលការណ៍នៃការប្រើប្រាស់មូលនិធិ ស.អ.។

## ៥. ការវិភាគ និងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការ

ផែនការនេះអនុវត្តក្នុងរយៈពេល ០២ឆ្នាំ (២០១៩-២០២០) ហើយត្រូវតាមដានរៀងរាល់ប្រាំមួយខែម្តង ដើម្បីពិនិត្យមើលពីៈ

- សមិទ្ធផលនៃការអនុវត្តផែនការ ចំនួនគម្រោងដែលត្រូវបានអនុវត្ត
- លទ្ធផលនៃការអនុវត្តផែនការ និងអនុសាសន៍កែប្រែសម្រាប់ការរៀបចំនិងប្រើប្រាស់មូលនិធិនេះបន្តទៀត
- ឥទ្ធិពលរយៈពេលវែងនៃផែនការនេះចំពោះការជួយប្រែក្លាយកម្ពុជាជាសេដ្ឋកិច្ចឌីជីថល។ ការវាស់វែងត្រូវធ្វើឡើងនាចុងឆ្នាំ២០២០។

## ៦.ឯកសារយោង


- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤
- គោលនយោបាយអភិវឌ្ឍន៍វិស័យទ-ប.គ.ព. ២០២០
- គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០២៥
- របាយការណ៍ស្តីពី "Cambodia's Vibrant Tech Startup Ecosystem 2018", Mekong Strategic Partner and Raintree, 2018